ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

**អង្គភាពគាំពារជនរងគ្រោះ**

Victims Support Section
Section d'appui aux victimes

ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១៤

# សេចក្តីជូនដំណឹង

## អង្គភាពគាំពារជនរងគ្រោះនឹងរៀបចំកិច្ចប្រជុំរវាងដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២ នៅភ្នំពេញ

អង្គភាពគាំពារជនរងគ្រោះ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) នឹងរៀបចំកិច្ចប្រជុំរវាងដើមបណ្តឹងរដ្ឋប្បវេណីនិងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០២ ក្រោមអធិបតីភាព ឯកឧត្តម **ក្រាញ់ តូនី** ប្រធានការិយាល័យរដ្ឋបាលស្តីទី នៃ អ.វ.ត.ក និង ឯកឧត្តម **Joachim Baron von Marschall** ឯកអគ្គរដ្ឋទូតសាធារណរដ្ឋអាល្លឺម៉ង់ប្រចាំកម្ពុជា។ កិច្ចប្រជុំនេះ នឹងប្រព្រឹត្តទៅនៅថ្ងៃចន្ទ ទី០៦ ខែតុលា ឆ្នាំ២០១៤ នៅអគារ លេខ ១៩-២១ ផ្លូវ៣៣០ សង្កាត់បឹងកេងកងបី ខណ្ឌចំការមន រាជធានីភ្នំពេញ។ (អត្តសញ្ញាណរបស់ដើមបណ្តឹងរដ្ឋ ប្បវេណីនឹងត្រូវរក្សាជាសម្ងាត់)។

គោលបំណងនៃកិច្ចប្រជុំ រួមមាន (១) ផ្តល់ព័ត៌មានស្តីពីការប្រកាសសាលក្រមសំណុំរឿង ០០២/០១ ដល់ដើមបណ្តឹងរដ្ឋប្បវេណី និងផ្តល់ព័ត៌មានស្តីពីដំណើរការក្តីនៅ អ.វ.ត.ក (២) ផ្តល់ឱកាសឲ្យដើមបណ្តឹងរដ្ឋប្បវេណីបានជួបពិភាក្សាផ្ទាល់ជាមួយមេធាវីរបស់ខ្លួនស្តីពីបញ្ហាផ្សេងៗ ទាក់ទងនឹងសំណុំរឿង ០០២/០២ និង (៣) ផ្តល់ព័ត៌មានដល់ដើមបណ្តឹងរដ្ឋប្បវេណីស្តីពីការវិវត្តទៅនៃគម្រោងសំណងដើមបណ្តឹងរដ្ឋប្បវេណីសំណុំរឿង ០០២ និងវិធានការនានា មិនពាក់ព័ន្ធនឹងបច្ចេកទេសតុលាការ។

ដើមបណ្តឹងរដ្ឋប្បវេណីប្រមាណ២២០នាក់រួមទាំងជនរងគ្រោះដោយអំពើហិង្សាផ្លូវភេទនៅសម័យខ្មែរក្រហមផងនឹងត្រូវអញ្ជើញឲ្យមកចូលរួមក្នុងកិច្ចប្រជុំនេះ។ ពួកគាត់មកពីរាជធានីភ្នំពេញ និងខេត្តផ្សេងៗ ជារួមមានខេត្តកណ្តាល កំពង់ស្ពឺ កំពត ក្រចេះ បន្ទាយមានជ័យ ពោធិ៍សាត់ បាត់ដំបង កំពង់ឆ្នាំង កំពង់ចាម ស្ទឹងត្រែង ស្វាយរៀង ព្រៃវែង និងតាកែវ។

---

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

លោក **ហាង វណ្ណៈ** ប្រធានអង្គភាពគាំពារជនរងគ្រោះ

ទូរស័ព្ទចល័ត: (៨៥៥) ២៣ ៨៦១ ៨២២ អ៊ីម៉ែល: hang.vannak@eccc.gov.kh